រក្សាសិទ្ធិ © ពតិមាន :

© ២០០១ Project WorldReach © ២០០១ SEAN

រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)

Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)

SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

059KH01A-01

សៀវភៅ រ៉ូម :

ជីវិតប្រកបដោយជំនឿ



កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៥៩

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™



ហេតុអ្វីបានជាសាវ័កប៉ូលសរសេរសំបុត្រនេះ ?

ពួកអ្នកជឿនៅក្នុងក្រុមជំនុំនៅទីក្រុងរ៉ូមជា « សាសន៍ដទៃ » គឺថាមិនមែនជាជនជាតិយូដា ។ ប៉ុន្តែ មានគ្រីស្តជនយូដាមួយចំនួនបានមកបង្រៀនថា ដើម្បីអោយបានសង្គ្រោះ ពួកអ្នកជឿដែលជាសាសន៍ដទៃ មិនមែនគ្រាន់តែត្រូវជឿទុកចិត្តលើព្រះយេស៊ូប៉ុណ្ណោះទេ តែត្រូវគោរពតាមក្រិត្យវិន័យទាំងអស់នៃព្រះគម្ពីរសម្ពន្ធមេត្រីចាស់ដែរ ។

កំណត់ចំណាំ :

© Project WorldReach © SEAN

កំណត់ចំណាំ :

សាវ៉ែកប៉ូលមិនពេញចិត្តនឹងសេចក្តីបង្រៀនខុសឆ្គងនេះ ទាល់តែសោះ ហើយព្រះវិញ្ញាណព្រះជាម្ចាស់បានបណ្តាលអោយលោកសរសេរលិខិតផ្ញើទៅកាន់ពួកអ្នកជឿ នៅទីក្រុងរ៉ូមទាំងនោះ ដើម្បីពន្យល់ថា គោលដៅនៃក្រិត្យវិន័យ គឺបង្ហាញពីអំពើបាប មិនមែនសំរាប់អោយបានសង្គ្រោះទេ ។ ទោះជាយើងជាសាសន៍យូដា ឬសាសន៍ដទៃក៏ដោយ យើងបានសង្គ្រោះតែដោយសារព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ និង ដោយសារ**ជំនឿ**ប៉ុណ្ណោះ មិនមែនមកពីយើងសន្សំកុសលផលបុណ្យ ឬ ធ្វើតាមវិន័យនោះឡើយ ។

សាវ៉ែកប៉ូលសរសេរសំបុត្រទៅពួកអ្នកជឿនៅទីក្រុងរ៉ូម ដើម្បី :

☐ បញ្ជាក់ថា ពួកគេត្រូវតែចុះចូលធ្វើតាមក្រិត្យវិន័យ ។

☐ ពន្យល់ថា ពួកគេបានសង្គ្រោះតាមរយៈជំនឿ ។

សូមប្រៀបធៀបចំលើយរបស់អ្នកជាមួយនឹង រ៉ូម ៣:២៨ :

«ដ្បិតយើងយល់ថា ព្រះជាម្ចាស់ប្រោសមនុស្សឱ្យបានសុចរិត មកពីគេមានជំនឿ មិនមែនមកពីគេប្រព្រឹត្តតាមវិន័យនោះឡើយ » ។

ប្រធានបទសំខាន់ជាងគេរបស់សៀវភៅរ៉ូម

សំបុត្រនេះមានប្រធានបទ ដែលកសាងអ្នកជឿច្រើនណាស់ តែមានប្រធានបទមួយសំខាន់ជាងគេ ដែលប្រៀបដូចជាខ្សែអំបោះចងទំព័រទាំងអស់របស់សៀវភៅ តាំងពីដើមដល់ចប់ :



ខ្សែអំបោះនោះ គឺ : យើងបានសុចរិតដោយសារជំនឿ

«ដំណឹងល្អនេះ សំដែងអោយដឹងថា ព្រះជាម្ចាស់ប្រោសប្រទានអោយមនុស្សបានសុចរិត ដោយសារជំនឿ និង អោយគេកាន់តាមជំនឿ ដូចមានចែងទុកមកថា÷ "មនុស្សសុចរិតមានជីវិតរស់ដោយសារជំនឿ" » ។

(រ៉ូម ១:១៧)

កិច្ចការដែលត្រូវអនុវត្ត

- បង្រៀនក្រុមជំនុំរបស់អ្នកពីជំហានទាំងឡាយ សំរាប់ឈានទៅរកភាពចាស់ទុំខាងព្រលឹងវិញ្ញាណ ដែលដកស្រង់ពីសំបុត្រផ្ញើទៅគ្រីស្តបរិស័ទនៅទីក្រុងរ៉ូម ។

កំណត់ចំណាំ :

© Project WorldReach © SEAN

ព្រះជាម្ចាស់ប្រកាសថា អស់អ្នកណាដែលជ្បើលើព្រះគ្រីស្ត នឹងបានរួចពីទោសនៃអំពើបាប ហើយព្រះអង្គនឹងប្រទានព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គដល់ពួកគេ ដើម្បីអោយពួកគេអាចក្លាយជាបុត្រធីតារបស់ព្រះជាម្ចាស់ ។

លិខិតផ្ញើទៅគ្រីស្តបរិស័ទនៅទីក្រុងរ៉ូម ជាសេចក្តីប្រកាសអំពីសេរីភាព ។ ព្រះជាម្ចាស់ប្រកាសថា យើងបានរួចពីទោសនៃអំពើបាបតាមរយៈ :

☐ ជំនឿលើព្រះយេស៊ូគ្រីស្ត ។

☐ ការប្រព្រឹត្តតាមក្រិត្យវិន័យរបស់ព្រះជាម្ចាស់ ។

សូមប្រៀបធៀបចំលើយរបស់អ្នកជាមួយ រ៉ូម ៣:២២ :

«ព្រះជាម្ចាស់ប្រោសអ្នកដែលមានជំនឿលើព្រះយេស៊ូគ្រីស្ត អោយបានសុចរិត គឺព្រះអង្គធ្វើដូច្នេះចំពោះអស់អ្នកដែលជឿ» ។

«បងប្អូនអើយ ខ្ញុំសូមជាស់តឿនបងប្អូនអោយប្រុងប្រយ័ត្ននឹងពួកអ្នកដែលបង្កអោយមានការបាក់បែកគ្នា និង នាំអោយបងប្អូនរវាតចិត្តចេញពីជំនឿ ដោយគេប្រព្រឹត្តផ្ទុយពីសេចក្តីបង្រៀន ដែលបងប្អូនបានទទួល ។ សូមបងប្អូនចៀសចេញអោយឆ្ងាយពីអ្នកទាំងនោះទៅ ដ្បិតមនុស្សប្រភេទនេះ មិនបំរើព្រះគ្រីស្តជាអម្ចាស់នៃយើងទេ គឺគេបំរើក្រពះរបស់គេវិញ ហើយបញ្ឆោតអ្នកដែលមានចិត្តស្លូតត្រង់ ដោយប្រើពាក្យសំដីពីរោះៗ និង ពាក្យបញ្ចើចបញ្ចើ» ។

(រ៉ូម ១៦:១៧-១៨)



យើងត្រូវរស់នៅដោយជំនឿ ! ។ យើងមិនត្រឹមតែបានសង្គ្រោះដោយសារជំនឿ នៅពេលចាប់ផ្តើមជីវិតជាគ្រីស្តជនប៉ុណ្ណោះទេ គឺថែមទាំងយើងត្រូវបន្តរស់ដោយជំនឿរហូតដែរ ។ យើងបន្តរស់ដោយព្យាយាមក្នុងជំនឿជារៀងរាល់ថ្ងៃ ក្នុងគ្រប់កិច្ចការដែលយើងធ្វើ ។ មួយវិញទៀត យើងក៏បានសង្គ្រោះជារៀងរហូតដែរ ព្រោះយើងបានទទួលជីវិតអស់កល្ប ។

ជំនឿរបស់យើងដឹកនាំយើងអោយទទួលព្រះគ្រីស្ត ហើយ :

☐ បន្ទាប់មក យើងទីពឹងលើការប្រព្រឹត្តល្អរបស់យើង ។

☐ បង្រួបបង្រួមយើងជាមួយព្រះគ្រីស្តជារៀងរហូត ។

សូមផ្ទៀងផ្ទាត់ចំលើយរបស់អ្នក : គឺដោយសារជំនឿ យើងបានរួមជាមួយព្រះគ្រីស្តជារៀងរហូត ។

សូមផ្ទៀងផ្ទាត់ចំលើយរបស់អ្នកជាមួយនឹងបទគម្ពីរនេះ :

«ក៏ប៉ុន្តែ ខ្ញុំបានតាំងចិត្តប្រកាសដំណឹងល្អ តែនៅកន្លែងណាដែលគេមិនទាន់ឮព្រះនាមព្រះគ្រីស្តនៅឡើយ ដើម្បីចៀសវាងសង់ពីលើគ្រឹះ ដែលអ្នកផ្សេងបានចាក់រួចមកហើយ គឺអោយបានស្របតាមសេចក្តីដែលមានចែងទុកមកថា :"អស់អ្នកដែលមិនទាន់បានទទួលដំណឹងអំពីព្រះអង្គ មុខជាឃើញ ហើយអស់អ្នកដែលមិនទាន់បានឮ មុខជាបានយល់" » ។

(រ៉ូម ១៥:២០-២១)

ជនជាតិយូដាខ្លះចង់បង្ខំសាសន៍ដទៃ ឱ្យប្រតិបត្តិតាមក្រិត្យវិន័យរបស់សម្ពន្ធមេត្រីចាស់ ។ ពេលដែលលោកប៉ូលប្រកាសដំណឹងល្អ ពួកគេជំទាស់ប្រឆាំងនឹងលោក ដែលធ្វើអោយរាំងស្ទះការងាររបស់លោក ។ លោកប៉ូលមិនបានធ្វើដូចជាពួកគេនោះទេ ។

នៅក្នុងជំពូក ១៦ លោកប៉ូលសរសើរគ្រីស្តជនជាច្រើន និង ទទួលស្គាល់ការងាររបស់ពួកគេ ជាអ្នកបំរើរបស់ព្រះគ្រីស្ត ។ គាត់ប្រៀនប្រដៅប្រាប់ពួកគេពីអ្នក ដែលបំបែកបំបាក់ពួកជំនុំ :

«ដូច្នេះ ត្រូវទទួលគ្នាទៅវិញទៅមក ដោយរាក់ទាក់អោយបានដូច ព្រះគ្រីស្តទទួលបងប្អូនដែរ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះ ជាម្ចាស់ ។ ខ្ញុំសូមជំរាបបងប្អូនថា ព្រះគ្រីស្តបានមកធ្វើជាអ្នកបំរើ របស់សាសន៍ ដែលកាត់ស្បែក ដើម្បីសំរេចតាមព្រះបន្ទូល ដែល ព្រះជាម្ចាស់បានសន្យាចំពោះបុព្វបុរស និង សំដែងព្រះហឫទ័យ សច្ចៈរបស់ព្រះអង្គ ។ រីឯសាសន៍ដទៃវិញ គេលើកតម្កើងសិរីរុង-រឿងរបស់ព្រះជាម្ចាស់ ដោយព្រះអង្គសំដែងព្រះហឫទ័យមេត្តា ករុណា...» ។

(រ៉ូម ១៥:៧-៩)

គ្រីស្តជនដែលមានអំនួត តែងតែចាប់ផ្តើមក្រុមជំនុំថ្មី ដោយលួច កូនចៀមពីក្រុមជំនុំឯទៀត ដែលខិតខំបំរើព្រះអង្គ ។
តើអ្នកបំរើដែលចេះបន្ទាបខ្លួន ត្រូវចាប់ផ្តើមធ្វើការផ្សាយដំណឹងល្អ នៅឯណា ?

☐ នៅកន្លែង ដែលគាត់អាចដណ្តើមយកសមាជិកពីក្រុមជំនុំ ផ្សេងទៀត ។

☐ នៅតាមទីកន្លែងដែលគ្មានក្រុមជំនុំ ហើយបណ្តាជនកំពុង បាត់បង់ខាងព្រលឹងវិញ្ញាណ ដោយគ្មានព្រះគ្រីស្ត ។

ជំហានសំរាប់ឈានទៅរកភាពចាស់ទុំខាងព្រលឹងវិញ្ញាណ

(សង្ខេបសំបុត្រផ្ញើទៅកាន់គ្រីស្តចរិសទនៅទីក្រុងរ៉ូម)

ជំហានសំរាប់ឈានទៅរកភាពចាស់ទុំខាងព្រលឹងវិញ្ញាណ មាន ចំនួន ១៣ ហើយគេចែកជាបួនដំណាក់ការ ។ មិនមែនមនុស្ស គ្រប់គ្នាត្រូវតែធ្វើតាមដំណើរការនេះ មួយដំណាក់ការ រួចបន្តទៅ ដំណាក់ការមួយទៀតនោះទេ ។ ជួនកាល ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើ ការតាមរបៀបមួយ ដែលធ្វើឱ្យមនុស្សធ្វើដំណាក់ការច្រើនរួមគ្នាតែ ម្តង ដូចជា ដំណាក់ការយល់ដឹងពីកំហុសរបស់ខ្លួន និង ដំណាក់ ការថ្វាយខ្លួន ។

ដំណាក់ការយល់ដឹងពីកំហុស (ជំពូក ១-៣)

១- មនុស្សមានបាបភ័យខ្លាចសេចក្តីក្រោធរបស់ព្រះជាម្ចាស់ (ការវិនិច្ឆ័យទោសមនុស្សលោក) ។

២- មនុស្សមានបាបឈប់ដោះសាខ្លួន ។

៣- មនុស្សមានបាបជឿថា ខ្លួនកំពុងបាត់បង់ ហើយបែរមក រកព្រះជាម្ចាស់វិញ ។

ដំណាក់ការថ្វាយខ្លួន (ជំពូក ៤-៦)

៤- អ្នកជឿបានទទួលព្រះបន្ទូលសន្យា ដែលជាការសង្គ្រោះ ដោយសារជំនឿ ។

៥- អ្នកជឿមានសន្តិភាពជាមួយព្រះជាម្ចាស់ ។

៦- អ្នកជឿបានជាប់ឆ្កាងជាមួយព្រះគ្រីស្ត ហើយរស់ឡើងវិញ ដើម្បីអោយមានជីវិតថ្មី ។

ដំណាក់ការរីកចំរើនឡើង (ជំពូក ៧-១១)

៧- មនុស្សដែលរស់នៅតាមព្រះវិញ្ញាណ តយុទ្ធនឹងនិស្ស័យសាច់ឈាមរបស់ខ្លួន ។

៨- មនុស្សដែលរស់នៅតាមព្រះវិញ្ញាណ មានសុវត្ថិភាពដោយ-សារព្រះគ្រីស្ត ។

៩- មនុស្សដែលរស់នៅតាមព្រះវិញ្ញាណ ពេញចិត្តនឹងបូសគល់ខាងព្រលឹងវិញ្ញាណរបស់ខ្លួន ។

ជំហាន ទី ១៣ : អ្នកជឿដែលចាស់ទុំខាងព្រលឹងវិញ្ញាណ ក្លាយជាអ្នកបំរើដែលចេះបន្ទាបខ្លួន ។
(អានជំពូក ១៥-១៦)

គ្រីស្តជនចាស់ទុំ :

☐ អធិប្បាយបានល្អជាងគេ ។

☐ ជាអ្នកដែលបញ្ជាគេ ច្រើនជាងធ្វើខ្លួនឯង ។

☐ បំរើមនុស្សឯទៀត ដោយបន្ទាបខ្លួនដូចព្រះគ្រីស្ត ។

«យើងម្នាក់ៗគោងតែខំធ្វើឱ្យអ្នកជំទែពេញចិត្ត ដើម្បីជាប្រយោជន៍ល្អដល់គេ និង ជួយគេអោយចំរើនឡើង ដ្បិតព្រះគ្រីស្តពុំបានស្វែងរកអ្វី ដែលធ្វើអោយគាប់ព្រះហឫទ័យរបស់ព្រះអង្គផ្ទាល់នោះឡើយ...» ។

(រ៉ូម ១៥:២-៣)



តើអ្នកណាត្រូវចុះចូល (ជួយ) អ្នកណា ?

☐ អ្នកមានជំនឿខ្សោយត្រូវចុះចូល (ជួយ)អ្នកមានជំនឿមាំមួន ។

☐ អ្នកមានជំនឿមាំមួនត្រូវចុះចូល(ជួយ)អ្នកមានជំនឿខ្សោយ។

សូមផ្ទៀងផ្ទាត់ចំលើយរបស់អ្នកជាមួយនឹង រ៉ូម ១៥:១ ។ ពេលយើងធ្វើអ្វីមួយ យើងត្រូវគិតដល់អ្នកដទៃ ។

ជំណាក់ការចាស់ទុំខាងព្រលឹងវិញ្ញាណ (ជំពូក ១២-១៦)

១០- អ្នកជឿដែលចាស់ទុំខាងព្រលឹងវិញ្ញាណ ថ្វាយខ្លួនទៅព្រះអង្គ ទុកជាយញ្ញបូជាដ៏មានជីវិត ។

១១- អ្នកជឿដែលចាស់ទុំខាងព្រលឹងវិញ្ញាណ ទទួលខុសត្រូវបំពេញភារៈកិច្ចខ្លួន ។

១២- អ្នកជឿដែលចាស់ទុំខាងព្រលឹងវិញ្ញាណ អត់ធ្មត់ជាមួយបងប្អូន ដែលមានជំនឿខ្សោយជាងខ្លួន ។

១៣- អ្នកជឿដែលចាស់ទុំខាងព្រលឹងវិញ្ញាណ ក្លាយជាអ្នកបំរើដែលចេះបន្ទាបខ្លួន ។

© Project WorldReach © SEAN

ដំណាក់ការយល់ដឹងពីកំហុស

(ជំពូក ១-៣)



ជំហាន ទី ១ : មនុស្សមានបាបភ័យខ្លាចសេចក្តីក្រោធរបស់ព្រះជាម្ចាស់ ។

(អានជំពូក ១)

មនុស្សមានបាប ត្រូវភ័យខ្លាចសេចក្តីក្រោធរបស់ព្រះជាម្ចាស់ ពីព្រោះ :

☐ គេដឹងថា គេសមនឹងទទួលការវិនិច្ឆ័យទោស ដោយសារតែអំពើទុច្ចរិតរបស់ខ្លួនគេ ។

☐ គេគិតថា ព្រះជាម្ចាស់នឹងដាក់ទោសគេយ៉ាងអយុត្តិធម៌ ។

បើតាមសាវ័កប៉ូល តើយើងគួរចៀសវាងអ្វីខ្លះ ?

☐ អ្វីៗដែលនាំអោយមនុស្សឯទៀតទាស់ចិត្ត ចុះខ្សោយ ឬធ្លាក់ចុះ ។

☐ អ្វីៗដែលនិកាយខុសឆ្គងហាមឃាត់ ។

សូមធ្វើងផ្ទាត់ចំលើយរបស់អ្នកជាមួយ រ៉ូម ១៤:១៧-២១ ។

«ចំពោះយើងដែលមានជំនឿមាំមួន យើងមានភារៈកិច្ចជួយអ្នកដែលមានជំនឿទន់ខ្សោយ គឺមិនត្រូវធ្វើអ្វីអោយតែខ្លួនឯងពេញចិត្តនោះឡើយ » ។

(រ៉ូម ១៥:១)

មនុស្សដែលមានជំនឿខ្សោយ ជាមនុស្សដែលគ្មានព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំ តែធ្វើតាមក្រិត្យវិន័យ ។ ឧទាហរណ៍ មនុស្សដែលមានជំនឿខ្សោយ មិនបរិភោគចំណីអាហារខ្លះ មិនផឹកភេសជ្ជៈខ្លះ ហើយចាត់ទុកថ្ងៃខ្លះ ជាថ្ងៃសំខាន់ (រ៉ូម ១៤:២, ៥, ២១) ។

សូមគូសពីក្រោមលក្ខណៈរបស់ព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលមានក្នុង រ៉ូម **១៤:១៧** :

«ដ្បិតព្រះរាជ្យរបស់ព្រះជាម្ចាស់ មិនមែនអាស្រ័យនៅលើការស៊ីផឹកនោះទេ គឺអាស្រ័យនៅលើសេចក្តីសុចរិត សេចក្តីសុខសាន្ត និង អំណរដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធ » ។

«ហេតុនេះហើយបានជាយើងត្រូវតែឈប់ថ្កោលទោសគ្នាទៅវិញទៅមក » ។

(រ៉ូម ១៤:១៣)

«ប្រសិនបើយើងមិនបរិភោគសាច់ មិនពិសាស្រា និង មិនប៉ះពាល់របស់ណាដែលធ្វើអោយបងប្អូនជំពប់ចិត្តបាត់ជំនឿនោះ ជាការល្អប្រពៃហើយ » ។

(រ៉ូម ១៤:២១)

សូមប្រៀបធៀបចំលើយរបស់អ្នកជាមួយ រ៉ូម **១:១៨** :

«ព្រះជាម្ចាស់សំដែងព្រះពិរោធពីស្ថានបរមសុខមក ប្រឆាំងនឹងការមិនគោរពប្រណិប័តន៍ព្រះអង្គ ប្រឆាំងនឹងអំពើទុច្ចរិតគ្រប់យ៉ាងដែលមនុស្សលោកប្រព្រឹត្ត ទាំងយកអំពើទុច្ចរិតនោះ ខ្ទប់សេចក្តីពិត មិនអោយលេចចេញមក...» ។

ជំហាន ទី ២ : មនុស្សមានបាបឈប់ដោះសាខ្លួន ។
(អានជំពូក ២)

ពាក្យដោះសា



« ចំពោះអ្នក... ក៏អ្នកពុំអាចដោះសាខ្លួនបានដែរ ។ ក៏ប៉ុន្តែ ដោយអ្នកមានចិត្តរឹងរូស មិនព្រមកែប្រែចិត្តគំនិតទេនោះ អ្នកកំពុងតែសន្សំទោសទុកសំរាប់ថ្ងៃព្រះជាម្ចាស់ទ្រង់ព្រះពិរោធ ជាថ្ងៃដែលព្រះអង្គនឹងសំដែងការវិនិច្ឆ័យទោសដោយយុត្តិធម៌ គឺព្រះជាម្ចាស់នឹងប្រទានផលអោយម្នាក់ៗ តាមអំពើដែលខ្លួនបានប្រព្រឹត្ត » ។

(រ៉ូម ២:១, ៥-៦)

ពាក្យដោះសា



« ដ្បិតព្រះជាម្ចាស់មិនរើសមុខនរណាឡើយ ។ អស់អ្នកដែលប្រព្រឹត្តអំពើបាប ដោយមិនស្គាល់គម្ពីរវិន័យរបស់លោកម៉ូសេ នឹងត្រូវវិនាសទាំងគ្មានគម្ពីរវិន័យ ។ រីឯអស់អ្នកដែលប្រព្រឹត្តអំពើបាបដោយស្គាល់គម្ពីរវិន័យ គេនឹងត្រូវទទួលទោស ស្របតាមគម្ពីរវិន័យនោះដែរ » ។

(រ៉ូម ២:១១-១២)

មនុស្សដែលរស់នៅតាមព្រះវិញ្ញាណ ចេះស្រឡាញ់ព្រះជាម្ចាស់ និង មនុស្សឯទៀត ។ បំណងប្រាថ្នារបស់គាត់សុទ្ធតែត្រឹមត្រូវ និង កើតមានដោយសារគាត់ស្រឡាញ់ព្រះជាម្ចាស់ និង ចង់ធ្វើតាមព្រះហឫទ័យព្រះអង្គ ។

បុត្រធីតារបស់ព្រះជាម្ចាស់ មានសេរីភាពអាច :

☐ មិនស្តាប់បង្គាប់រដ្ឋអំណាច ។

☐ បំរើព្រះជាម្ចាស់ ដោយសេចក្តីស្រឡាញ់ ។

សូមផ្ទៀងផ្ទាត់ចំលើយរបស់អ្នកជាមួយនឹង រ៉ូម ១៣:៤-៨ ។

ជំហាន ទី ១២ : អ្នកជឿដែលចាស់ទុំខាងព្រលឹងវិញ្ញាណ អត់ធ្មត់ជាមួយបងប្អូន ដែលមានជំនឿខ្សោយជាងខ្លួន ។
(អានជំពូក ១៤ និង ១៥:១)

សូមគូសពីក្រោមអ្នកដែលយើងត្រូវទទួល ដោយមិនរិះគន់ :

« ចូរទទួលបងប្អូនណាដែលមានជំនឿទន់ខ្សោយ ដោយរាក់ទាក់ មិនត្រូវរិះគន់យោបល់របស់គេឡើយ » ។

(រ៉ូម ១៤:១)

យើងលែងស្ថិតនៅក្រោមក្រិត្យវិន័យនៃសម្ពន្ធមេត្រីចាស់ទៀតហើយ ។ យោងទៅតាម រ៉ូម ១៣:៨-១០ តើពេលនេះ យើងត្រូវធ្វើតាមក្រិត្យវិន័យណា ?

☐ សេចក្តីស្រឡាញ់ ដែលធ្វើអោយយើងអាចប្រតិបត្តិតាមគម្ពីរវិន័យគ្រប់យ៉ាង ។

☐ ក្រិត្យវិន័យរបស់លោកម៉ូសេ ។

អ្នកដែលមានជំនឿខ្សោយ ខំពឹងលើក្រិត្យវិន័យ ។ ហេតុនេះហើយបានជាគាត់មិនមានសេរីភាពធ្វើកិច្ចការគ្រប់យ៉ាង ដែលព្រះជាម្ចាស់អនុញ្ញាតអោយគាត់ធ្វើទេ ។ គាត់នៅតែកាន់ក្បួនតម្រានៅឡើយ ដែលនាំអោយគាត់អាចបំពេញត្រឹមតែសេចក្តីប៉ងប្រាថ្នារបស់លោកីយ៌ប៉ុណ្ណោះ ។



ពាក្យដោះសា



«សាសន៍យូដាដ៏ពិតប្រាកដ មិនស្ថិតនៅត្រង់សំបកក្រៅទេ រីងការកាត់ស្បែកដ៏ពិតប្រាកដ ក៏មិនស្ថិតនៅត្រង់សញ្ញាលើរូបកាយនោះដែរ សាសន៍យូដាដ៏ពិតប្រាកដសំដៅទៅផ្នែកខាងក្នុងចិត្តឯណោះវិញ រីងការកាត់ស្បែកដ៏ពិតប្រាកដ ក៏ស្ថិតនៅលើចិត្តដែរ គឺជាការកាត់ស្បែក ស្របតាមព្រះវិញ្ញាណ...» ។

(រ៉ូម ២:២៨-២៩)

តើយើងអាចដោះសាដូចម្តេចខ្លះ នៅចំពោះព្រះភ័ក្ត្ររបស់ព្រះជា-ម្ចាស់ ?

☐ « យើងទទួលភាពទន់ខ្សោយពីអដាម » ។

☐ « អ្នកឯទៀតប្រព្រឹត្តអាក្រក់ជាងខ្ញុំផង » ។

☐ នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ យើងពុំអាចដោះសាបានទេ ។

ជំហាន ទី ៣ : មនុស្សមានបាបជឿថា ខ្លួនកំពុងបាត់បង់ ហើយបែរមករកព្រះជាម្ចាស់វិញ ។
(អានជំពូក ៣)

តើក្រិត្យវិន័យមានគោលបំណងដូចម្តេច ?

☐ ធ្វើអោយមនុស្សដឹងថា ខ្លួនប្រព្រឹត្តអំពើបាប ។

☐ ប្រោសអ្នកដែលឈប់ប្រព្រឹត្តអំពើបាប អោយបានសុចរិត ។

សូមប្រៀបធៀបចំលើយរបស់អ្នក ជាមួយឃ្លាចុងក្រោយរបស់គម្ពីរ រ៉ូម ៣:១៩-២០ ដែលចែងថា៖

សូមគូសពីក្រោមអ្នកដែលរដ្ឋអំណាចត្រូវដាក់ទោស :

(រដ្ឋាភិបាលនៅលើផែនដី) « ដ្បិតលោកទាំងនោះជាអ្នកបំរើព្រះ-ជាម្ចាស់ ដើម្បីជំរុញអ្នកអោយប្រព្រឹត្តល្អ ។ ផ្ទុយទៅវិញ បើអ្នកប្រព្រឹត្តអំពើអាក្រក់ ចូរខ្លាចទៅ ដ្បិតអាជ្ញាធរមិនមែនកាន់អំណាចជាអាសារឥតការទេ គឺគេជាអ្នកបំរើព្រះជាម្ចាស់ ដើម្បីធ្វើទណ្ឌកម្មដាក់ទោសអ្នកដែលប្រព្រឹត្តអំពើអាក្រក់ » ។

(រ៉ូម ១៣:៤)

សូមគូសពីក្រោមភារៈកិច្ចបួន ដែលយើងត្រូវបំពេញ :

« ត្រូវជូនលោកទាំងនោះនូវអ្វីដែលបងប្អូនត្រូវជូន គឺបង់អាករទៅលោកណា ដែលបងប្អូនត្រូវបង់ បង់ពន្ធទៅលោកណា ដែលបងប្អូនត្រូវបង់ពន្ធ កោតខ្លាចលោកណា ដែលបងប្អូនត្រូវកោតខ្លាច គោរពលោកណា ដែលបងប្អូនត្រូវគោរព ។ មិនត្រូវជំពាក់អ្វីនរណា ក្រៅពីជំពាក់សេចក្តីស្រឡាញ់គ្នាទៅវិញទៅមកនោះឡើយ ដ្បិតអ្នកណាស្រឡាញ់អ្នកដទៃ អ្នកនោះប្រតិបត្តិតាមគម្ពីរវិន័យសព្វគ្រប់ហើយ » ។

(រ៉ូម ១៣:៧-៨)

សូមផ្ទៀងផ្ទាត់ចំលើយរបស់អ្នក ដោយអាន រ៉ូម ១២:១-២ សាឡើងវិញ ។

គ្រូគង្វាលត្រូវតែកសាងជំនឿរបស់កូនចៀមរបស់ខ្លួន អោយចំរើនឡើងជាប់ជានិច្ច ដើម្បីអោយពួកគេអាចថ្វាយខ្លួនទៅ ព្រះជាម្ចាស់ ទុកជាយញ្ញបូជាដ៏មានជីវិត ។

ជំហាន ទី ១១ : អ្នកជឿចាស់ទុំខាងព្រលឹងវិញ្ញាណទទួលខុសត្រូវបំពេញភារៈកិច្ចខ្លួន ។
(អានជំពូក ១៣)

សូមគូសពីក្រោមអ្នកដែលយើងត្រូវគោរពចុះចូល :

« មនុស្សគ្រប់រូបត្រូវស្តាប់បង្គាប់អាជ្ញាធរ ដ្បិតអំណាចទាំងឡាយសុទ្ធតែមកពីព្រះជាម្ចាស់ គឺព្រះអង្គបានតែងតាំងឱ្យមានអំណាចទាំងនោះឡើង » ។

(រ៉ូម ១៣:១)

« យើងដឹងថា គ្រប់សេចក្តីដែលមានចែងទុកក្នុងគម្ពីរវិន័យ សុទ្ធតែចែងទុកសំរាប់អស់អ្នកដែលចំណុះវិន័យ ដើម្បីកុំអោយមនុស្សណាម្នាក់រកពាក្យដោះសាបាន ហើយអោយពិភពលោកទាំងមូលទទួលទោស នៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ។ ដូច្នេះ គ្មាននរណាម្នាក់បានសុចរិតនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ដោយការប្រព្រឹត្តតាមវិន័យនោះទេ ព្រោះវិន័យគ្រាន់តែនាំអោយគេស្គាល់អំពើបាបប៉ុណ្ណោះ » ។

« ... គ្រប់ៗគ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ » ។

(រ៉ូម ៣:២៣)

គ្មានអ្នកណាអាចសង្គ្រោះខ្លួនឯង ឬក៏ចៀសផុតពីលទ្ធផលនៃអំពើបាបរបស់ខ្លួន ដែលត្រូវតែកើតមាននោះបានទេ ។ សេចក្តីសង្ឃឹមតែមួយរបស់មនុស្សមានបាប គឺត្រូវបន្ទាបខ្លួន និង ស្វែងរកសេចក្តីមេត្តាករុណាពីព្រះជាម្ចាស់ប៉ុណ្ណោះ ។



ដើម្បីទុកខ្លួនជាយញ្ញបូជាដ៏មានជីវិតថ្វាយព្រះជាម្ចាស់យើង :

ខ ២ : ត្រូវឱ្យព្រះជាម្ចាស់កែប្រែចិត្តគំនិតយើងឱ្យទៅជាថ្មី ។

ខ ៣ : ត្រូវគិតឱ្យបានសមរម្យពីខ្លួនឯង តាមកិរិតនៃជំនឿ ។

ខ ៤-៨ : ត្រូវប្រើប្រាស់អំណោយទានរបស់ខ្លួនក្នុងរូបកាយតែមួយ ។

ខ ៩-១០ : ត្រូវមានចិត្តស្រឡាញ់ ដោយស្មោះ ។

ខ ១១-១២ : ត្រូវឧស្សាហ៍ខ្នះខ្នែង កុំខ្ជិលច្រអូស ។

ខ ១២-១៣ : ត្រូវជួយអ្នកខ្វះខាត ។

ខ ១៤-១៥ : ត្រូវប្រុងប្រយ័ត្នចំពោះពាក្យសំដីរបស់ខ្លួន ។

ខ ១៦ : មិនត្រូវមានគំនិតលើកខ្លួនឡើយ តែត្រូវចាប់ចិត្តនឹងអ្វីៗដែលទន់ទាបវិញ ។

ខ ១៧-២១ : ត្រូវឈ្នះការអាក្រក់ ដោយប្រព្រឹត្តអំពើល្អ ។

ការថ្វាយបង្គំដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់បំផុត គឺ :

☐ ការសរសើរតម្កើងនៅចំពោះមនុស្សជាច្រើន ។

☐ ការថ្វាយជីវិតទាំងស្រុង ទុកជាយញ្ញបូជាសំរាប់ព្រះជាម្ចាស់ ។

© Project WorldReach © SEAN

ជំណាក់ការចាស់ទុំខាងព្រលឹងវិញ្ញាណ

(ជំពូក ១២-១៦)

ជំហាន ទី ១០ : អ្នកជឿដែលចាស់ទុំខាងព្រលឹងវិញ្ញាណ ថ្វាយខ្លួនទៅព្រះអង្គ ទុកជាយញ្ញបូជា ដ៏មានជីវិត ។

(អានជំពូក ១២)

សង្ខេបបទគម្ពីរ រ៉ូម ជំពូក ១២

ប្រធានបទ : រ៉ូម ១២:១ *«ខ្ញុំសូមជាស់តឿនបងប្អូនថា ដោយព្រះជាម្ចាស់មានព្រះហឫទ័យអាណិតអាសូរបងប្អូន ចូរថ្វាយខ្លួនទៅព្រះអង្គ ទុកជាយញ្ញបូជាដ៏មានជីវិត ជិវិសុទ្ធ ហើយជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ បើបងប្អូនធ្វើដូច្នេះ ទើបហៅថាគោរពបំរើព្រះអង្គតាមរបៀបត្រឹមត្រូវមែន »* ។

ជំណាក់ការថ្វាយខ្លួន

(ជំពូក ៤-៦)

ជំហាន ទី ៩ : អ្នកជឿទទួលបានព្រះបន្ទូលសន្យា ដែលជាការសង្គ្រោះ ដោយសារជំនឿ ។

(អានជំពូក ៤)

ព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណាណាស់ ហើយព្រះអង្គបានប្រទានអោយព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូគ្រីស្តយាងមកចេញថ្លៃលោះយើងអោយរួចពីទោសដែលយើងត្រូវទទួល ។ ព្រះយេស៊ូសុគតជំនួសយើង ។ ព្រះអង្គចេញថ្លៃខ្ពស់ណាស់ គឺបូជាព្រះជន្ម ដើម្បីប្រោសលោះយើង និង សង្គ្រោះយើង ។ បើសិនជាយើងមិនទទួលសេចក្តីសង្គ្រោះនេះ ដោយ**សារជំនឿ**ទេនោះ គ្មានសេចក្តីសង្គ្រោះណាផ្សេងទៀតទេ ហើយយើងនឹងបែកពីព្រះជា-ម្ចាស់ ជារៀងរហូត (រ៉ូម ៣:២៤-៣០) ។

ព្រះជាម្ចាស់សន្យានឹងលោកអប្រាហាំថា នឹងប្រទានពរដល់គ្រប់ជាតិសាសន៍តាមរយៈគាត់ ដោយយល់ដល់ជំនឿរបស់គាត់ តាំងពីមុនគាត់កាត់ស្បែក និង មុនដែលមានក្រិត្យវិន័យទៅទៀត ។

កូនដ៏ពិត និង អ្នកដែលពិតជាទទួលមរតករបស់លោកអប្រាហាំ គឺ :

☐ កូនចៅខាងសាច់ឈាមរបស់គាត់ ។

☐ អ្នកដែលប្រតិបត្តិតាមក្រិត្យវិន័យរបស់លោកម៉ូសេ ។

☐ អ្នកដែលមានជំនឿដូចគាត់ ។

ចំលើយ : សូមអានដោយហ្មត់ចត់ខគម្ពីរនេះ :

«ប្រសិនបើមនុស្សទទួលមតិក ដោយគោរពតាមវិន័យ នោះបានសេចក្តីថា ជំនឿគ្មានប្រយោជន៍អ្វីសោះ ហើយព្រះបន្ទូលសន្យាសោតក៏គ្មានតំលៃអ្វីដែរ... ព្រោះតែជំនឿ មនុស្សទទួលមតិកតាមការប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដូច្នេះ ព្រះបន្ទូលសន្យារបស់ព្រះអង្គ មានប្រយោជន៍សំរាប់ពូជពង្សលោកអប្រាហាំទាំងមូល មិនត្រឹមតែអស់អ្នកដែលប្រតិបត្តិតាមវិន័យប៉ុណ្ណោះទេ គឺសំរាប់អស់អ្នក ដែលមានជំនឿដូចលោកអប្រាហាំ ជាឪពុករបស់យើងទាំងអស់គ្នានោះដែរ » ។

(រ៉ូម ៤:១៤, ១៦)

ជនជាតិយូដាត្រូវកាត់ចោល ព្រោះពួកគេគ្មានជំនឿ ។

ពួកអ្នកជឿ ដែលមិនមែនជាជនជាតិយូដា :

☐ គ្មានសិទ្ធិធ្វើជាប្រជាជនរបស់ព្រះរាជ្យព្រះជាម្ចាស់ទេ ។

☐ ជាមែកអូលីវព្រៃផ្សាំនឹងដើមអូលីវ ។

យើងមិនត្រូវលើកតម្កើងខ្លួន ដោយសារបានទទួលសេចក្តីសន្យាដែលព្រះជាម្ចាស់ប្រទានអោយជនជាតិយូដាទេ ។ យើងមិនមែនប្រសើរជាងពួកគេទេ ។ យើងជាមែកអូលីវព្រៃ ដែលត្រូវបានផ្សាំក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ដោយសារព្រះហឫទ័យមេត្តាករុណាសុទ្ធសាធ ។

ដើមអូលីវតំណាងប្រជារាស្ត្រដ៏ពិតនៃព្រះជាម្ចាស់ ដែលជាកូនចៅដ៏ពិតរបស់លោកអប្រាហាំ និង ដែលជាជនជាតិអ៊ីស្រាអែលរបស់ព្រះជាម្ចាស់ ។

តើអ្នកណាជាមែកធម្មជាតិ (មែកដើម) របស់ដើម ?

☐ ជនជាតិយូដា (ជនជាតិអ៊ីស្រាអែល) ។

☐ ពួកអ្នកជឿគ្រប់ជាតិសាសន៍ ។

ហេតុអ្វីបានជាមែកធម្មជាតិ គឺពួកជនជាតិអ៊ីស្រាអែល ត្រូវកាត់ចោល ?

☐ ព្រោះមែកទាំងនោះគ្មានជំនឿ ។

☐ ព្រោះមែកទាំងនោះមិនស្វាហាប់ ។



សេចក្តីសំខាន់ គឺត្រូវបញ្ជាក់ថា ជំនឿដែលសង្គ្រោះនេះ មិនមែនគ្រាន់តែជាជំនឿតាមប្រាជ្ញារបស់មនុស្សប៉ុណ្ណោះទេ ព្រោះព្រះគម្ពីរចែងថា សូម្បីតែអារក្សក៏ជឿ ហើយថែមទាំងភ័យញាប់ញ័រទៀតផង (យ៉ាកុប ២:១៩) ។

ជំនឿដែលសង្គ្រោះមានន័យថា :

១- « ការកែប្រែចិត្តគំនិត »

កាលពីដើមមនុស្សបាបបានដើរឆ្ពោះទៅរកអំពើបាប ។ ការកែប្រែចិត្តគំនិត គឺជាការដែលមនុស្សបាបបែរចេញពីអំពើបាប ហើយដើរឆ្ពោះទៅរកព្រះជាម្ចាស់វិញ ។ អ្នកដែលកែប្រែចិត្តគំនិត លះបង់អំពើបាបចេញ ហើយទទួលជឿព្រះអម្ចាស់យេស៊ូ ។

« កាលបណ្តាជនបានឮសេចក្តីទាំងនេះ ពួកគេរំជួលចិត្តជាខ្លាំង ហើយសួរលោកពេត្រុស / សិលា និង គ្រីស្តទូតឯទៀតៗថា÷ "បងប្អូនអើយ ! តើអោយយើងខ្ញុំធ្វើដូចម្តេច ?" ។ លោកពេត្រុស / សិលាមានប្រសាសន៍ទៅគេថា÷ "សូមបងប្អូនកែប្រែចិត្តគំនិត" » ។

(កិច្ចការ ២:៣៧-៣៨)



នៅក្នុងសម្ពន្ធមេត្រីចាស់ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ជា :

☐ ជនជាតិអ៊ីស្រាអែល (យូដា) ។

☐ សាសន៍ដទៃ (មិនមែនជាសាសន៍យូដា) ។

☐ មនុស្សទាំងអស់ ។

ព្រះជាម្ចាស់បានចងសម្ពន្ធមេត្រីចាស់ តែជាមួយជាតិសាសន៍មួយប៉ុណ្ណោះ ។ ជនជាតិអ៊ីស្រាអែលនេះ ជាកូនចៅរបស់លោកអ្រាហាំ ជាសាច់ឈាមខាងអ៊ីសាក់ ដែលជាកូនប្រុសតាត់ ។

ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ នៅក្នុងសម្ពន្ធមេត្រីថ្មីជា :

☐ ជនជាតិអ៊ីស្រាអែល (យូដា) ។

☐ ពួកអ្នកជឿគ្រប់ជាតិសាសន៍ ។

ពួកអ្នកជឿជាតិសាសន៍ណាក៏ដោយ ក៏សុទ្ធតែជាកូនចៅដ៏ពិតខាងព្រលឹងវិញ្ញាណរបស់អ្នកជឿអ្រាហាំដែរ ។ ព្រះជាម្ចាស់បានសន្យាជាមួយដួនតារបស់ជនជាតិយូដា និង របស់ព្រះយេស៊ូនេះថា÷ *« ក្រុមគ្រួសារទាំងអស់នៅលើផែនដី នឹងបានទទួលពរដោយសារអ្នក »* (កំណើតពិភពលោក ១២:១-៣) ។



«...ក្រែងលោបងប្អូនស្មានថាខ្លួនឯងមានប្រាជ្ញា ។ គំរោងការដ៏លាក់កំបាំងនោះ គឺសាសន៍អ៊ីស្រាអែលមួយចំនួនមានចិត្តរឹងរូសរហូតដល់ពេលសាសន៍ដទៃទាំងអស់ បានចូលមកទទួលការសង្គ្រោះ ពេលនោះ ទើបសាសន៍អ៊ីស្រាអែលទាំងមូលនឹងទទួលការសង្គ្រោះដែរ ដូចមានចែងទុកមកថា : "ព្រះអង្គដែលរំដោះនឹងយាងចេញពីក្រុងស៊ីយ៉ូន ព្រះអង្គនឹងដកអំពើទមិឡចេញពីកូនចៅលោកយ៉ាកុប" » ។

(រ៉ូម ១១:២៥-២៦)

២- «ទទួលព្រះយេស៊ូគ្រីស្តជាព្រះសង្គ្រោះ និង ព្រះអម្ចាស់» ។

«រីឯអស់អ្នកដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿលើព្រះនាមព្រះអង្គ ព្រះអង្គប្រទានអោយគេអាចទៅជាបុត្រធីតារបស់ព្រះជាម្ចាស់» ។

(យ៉ូហាន ១:១២)



៣- « ប្រតិបត្តិតាមព្រះជាម្ចាស់ » ។

« អ្នកដែលចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ មិនមែនជាអ្នក ដែលគ្រាន់តែហៅខ្ញុំថា "ព្រះអម្ចាស់ ! ព្រះអម្ចាស់ !" ប៉ុណ្ណោះ ទេ គឺជាអ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់ នៅស្ថានបរមសុខនោះវិញ » ។

(ម៉ាថាយ ៧:២១)

ជំហាន ទី ៥ : អ្នកឈ្មើមានសន្តិភាពជាមួយព្រះជាម្ចាស់ ។
(ជំពូក ៥)

« ព្រះហឫទ័យប្រណីសន្តោស » មានន័យថា សេចក្តីដ៏ល្អ ហើយ និង ផលប្រយោជន៍ ដែលយើងមិនសមនឹងបានទទួល តែព្រះបិតា របស់យើង ដែលគង់នៅស្ថានបរមសុខ ប្រទានអោយយើង ។
យើងបានសង្គ្រោះ :

☐ អោយរួចផុតពីអំពើបាបពីមុនប៉ុណ្ណោះ ។

☐ អស់កល្បជានិច្ច ពីព្រោះយើងមានសង្ឃឹមយ៉ាងខ្លាំងថា នឹង បានទទួលសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដោយសារព្រះ-ហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ ។

នៅក្នុង រ៉ូម ១១:១៧-២១ លោកប៉ូលពន្យល់ពី « ការផ្សាំព្រលឹង វិញ្ញាណ » ។ ជនជាតិយូដាជាមែកអូលីវដែលត្រូវកាត់ចេញពីដើម ដោយសារពួកគេគ្មានជំនឿ ។ រីឯពួកដែលមិនមែនជាជនជាតិ យូដា (សាសន៍ដទៃ) ជាមែកអូលីវព្រៃ ដែលគេយកទៅផ្សាំនឹង ដើមអូលីវ ។ ហេតុអ្វីបានជាសាសន៍ដទៃទាំងនេះ មិនត្រូវអួតខ្លួន ដោយសារបានផ្សាំជាមួយដើមអូលីវ ? ។

« សាសន៍អ៊ីស្រាអែលប្រៀបបីដូចជាដើមអូលីវ ដែលគេកាត់មែក ខ្លះចោល រីឯអ្នកវិញ អ្នកប្រៀបបីដូចជាមែកអូលីវព្រៃ ត្រូវគេ យកមកផ្សាំជំនួសមែក ដែលគេកាត់ចោលនោះ ។ ឥឡូវនេះ អ្នក ស្រូបយកជីជាតិពីឫសរួមជាមួយមែកឯទៀតៗដែរ ដូច្នេះ អ្នកមិន ត្រូវអួតខ្លួន ដោយមើលងាយមែកដែលគេកាត់ចោលនោះឡើយ។ បើអ្នកចង់អួតខ្លួន គោងជឿងថា មិនមែនអ្នកទេ ដែលចិញ្ចឹមឫស គឺឫសវិញទេតើ ដែលចិញ្ចឹមអ្នក ! » ។

(រ៉ូម ១១:១៧-១៨)

ជំនឿកើតមកពីសេចក្តីដែលយើងបានស្តាប់ ឯសេចក្តីដែលយើងបានស្តាប់នោះកើតមកពីណា ? ។ _____

សូមផ្ទៀងផ្ទាត់ចំលើយរបស់អ្នកជាមួយ :

«...ជំនឿកើតមកពីសេចក្តីដែលយើងបានស្តាប់ រីឯសេចក្តីដែលយើងបានស្តាប់នោះ កើតមកពីព្រះបន្ទូលរបស់ព្រះគ្រីស្ត » ។

(រ៉ូម ១០:១៧)

ជំនឿកើតឡើងដោយសារ :

☐ អារម្មណ៍ ឬ ទឹកចិត្តរបស់យើង ។

☐ បទពិសោធន៍របស់យើង ។

☐ ព្រះបន្ទូលព្រះជាម្ចាស់ ។

ព្រះវិញ្ញាណដ៏វិសុទ្ធបណ្តាលអោយមានជំនឿពិតប្រាកដ ក្នុងយើង តាមរយៈព្រះបន្ទូលព្រះជាម្ចាស់ ។ ត្រូវបង្រៀនសមាជិករបស់អ្នក កុំអោយទុកចិត្តលើសភាពទឹកចិត្តរបស់ខ្លួនឡើយ តែត្រូវទុកចិត្តលើព្រះបន្ទូលព្រះជាម្ចាស់វិញ ព្រោះព្រះបន្ទូលនៅស្ថិតស្ថេរជារៀងរហូត ។

សូមប្រៀបធៀបចំលើយរបស់អ្នកជាមួយបទគម្ពីរនេះ :

«ដូច្នេះ ដោយព្រះជាម្ចាស់ប្រោសយើងអោយបានសុចរិត ព្រោះតែយើងមានជំនឿ យើងក៏មានសន្តិភាពជាមួយនឹងព្រះអង្គ តាមរយៈព្រះយេស៊ូគ្រីស្ត ជាអម្ចាស់នៃយើងដែរ ។ ព្រោះតែព្រះគ្រីស្ត និង ដោយសារជំនឿ យើងមានមាគ៌ាចូលទៅកាន់ជីវិតថ្មី ហើយយើងក៏ស្ថិតនៅក្នុងជីវិតថ្មីនេះយ៉ាងខ្ជាប់ខ្ជួន ទាំងខ្ពស់មុខ ដោយសង្ឃឹមថា នឹងបានទទួលសិរីរុងរឿងរបស់ព្រះជាម្ចាស់ » ។

(រ៉ូម ៥:១-២)

ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ :

☐ មានកំណត់ ។

☐ បរិបូណ៌ហួរហៀរ ។

សូមប្រៀបធៀបចំលើយរបស់អ្នកជាមួយនឹងបទគម្ពីរ រ៉ូម ៥:១៩-២០ នៅទំព័របន្ទាប់ :

«ហើយមនុស្សទាំងអស់ជាប់បាប ដោយសារមនុស្សតែម្នាក់មិនស្តាប់បង្គាប់យ៉ាងណា ព្រះជាម្ចាស់ក៏នឹងប្រោសមនុស្សទាំងអស់អោយបានសុចរិត ដោយសារមនុស្សតែម្នាក់បានស្តាប់បង្គាប់យ៉ាងនោះដែរ ។ ព្រះជាម្ចាស់ប្រទានគម្ពីរវិន័យមក ដើម្បីអោយកំហុសចេញមុខកាន់តែច្រើនឡើងៗ ។ នៅទីណាដែលមានបាបកាន់តែច្រើន នៅទីនោះព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ក៏រីតតែមានច្រើនលើសលប់ថែមទៀត » ។

សង្ខេបសៀវភៅ រ៉ូម ជំពូក ៥

ផលផ្លែនៃជំនឿ :

១- រ៉ូម ៥:១ : សន្តិភាពជាមួយព្រះជាម្ចាស់

២- រ៉ូម ៥:២ : មាគ៌ាចូលទៅជួបព្រះជាម្ចាស់

៣- រ៉ូម ៥:២-៥ : មានក្តីសង្ឃឹម ពេលមានទុក្ខលំបាក

៤- រ៉ូម ៥:៦-៩ : ការលើកលែងទោស

៥- រ៉ូម ៥:១០-១១ : សំរុះសំរួលអោយជានានឹងព្រះជាម្ចាស់

៦- រ៉ូម៥:១២-១៨ : ជីវិតអស់កល្ប

៧- រ៉ូម ៥:១៩-២១ : ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ

«...ប្រសិនបើមាត់អ្នកប្រកាសថា ព្រះយេស៊ូពិតជាព្រះអម្ចាស់ ហើយបើចិត្តអ្នកជឿថា ព្រះជាម្ចាស់ពិតជាបានប្រោសព្រះយេស៊ូឱ្យមានព្រះជន្មរស់ឡើងវិញមែន នោះអ្នកនឹងទទួលការសង្គ្រោះជាមិនខាន » ។

(រ៉ូម ១០:៩)

យោងទៅតាមខទាំងនេះ តើជំនឿដ៏ពិតប្រាកដ គឺអ្វី ? ។

_____

សព្វថ្ងៃនេះ ចំពោះព្រះជាម្ចាស់ តើនៅក្នុងក្រុមជំនុំ/ព្រះសហគមន៍មានការខុសគ្នារវាងអ្នកជឿយូដា និង អ្នកជឿសាសន៍ដទៃដែរឬទេ ? ។_____

សូមផ្ទៀងផ្ទាត់ចំលើយរបស់អ្នកជាមួយនឹងបទគម្ពីរនេះ :

«ដូច្នេះ សាសន៍យូដា និង សាសន៍ក្រិក មិនប្លែកពីគ្នាត្រង់ណាទេ គេទាំងអស់គ្នាមានព្រះអម្ចាស់តែមួយ ដែលមានព្រះហឫទ័យទូលាយដល់អស់អ្នកអង្វរករព្រះអង្គ ដ្បិត "អ្នកណាអង្វរករព្រះនាមព្រះអម្ចាស់ អ្នកនោះនឹងទទួលការសង្គ្រោះ" » ។

(រ៉ូម ១០:១២-១៣)

© Project WorldReach © SEAN

អ្នកដែលទទួលមរតកនៃព្រះបន្ទូលសន្យារបស់ស្ថានបរមសុខ ជាអ្នកដែលជឿលើព្រះគ្រីស្ត ។ ពួកគេបានសង្គ្រោះ :

☐ ដោយសារជំនឿ និង ការប្រព្រឹត្តល្អ ។

☐ ដោយសារជំនឿ ដែលបណ្តាលអោយប្រព្រឹត្តល្អ ។

សូមធ្វើងផ្ទាត់ចំលើយរបស់អ្នកជាមួយនឹងបទគម្ពីរនេះ :

«...សាសន៍អ៊ីស្រាអែល គេខំប្រឹងប្រែងធ្វើតាមវិន័យ ដែលផ្តល់សេចក្តីសុចរិត តែពួកគេពុំបានសុចរិតតាមវិន័យនោះឡើយ ។ ហេតុអ្វីបានជាដូច្នេះ ? គឺមកពីពួកគេពឹងលើការប្រព្រឹត្តតាមវិន័យ មិនពឹងលើជំនឿទេ ។ ពួកគេជំពប់ដួលនឹង "ថ្មដែលនាំអោយគេជំពប់" ដូចមានចែងទុកមកថា :"យើងបានដាក់ថ្មមួយនៅក្រុងស៊ីយ៉ូន ជាថ្មដែលនាំអោយគេជំពប់ដួល ជាសិលាដែលនាំអោយគេរវាតចិត្តបាត់ជំនឿ អ្នកណាជឿលើថ្មនេះ អ្នកនោះមុខជាមិនខកចិត្តឡើយ" » ។

(រ៉ូម ៩:៣១-៣៣)

យើងមិនមែនបានសង្គ្រោះ ដោយសារយើងខំធ្វើខ្លួនអោយវិសុទ្ធទេ គឺព្រះជាម្ចាស់ទេ ដែលធ្វើឱ្យយើងបានសុចរិតដូចព្រះគ្រីស្ត ។ នេះជារបៀបដែលយើងបានសង្គ្រោះ ដោយសារព្រះហឫទ័យប្រណីសន្តោស គឺដោយសារព្រះជាម្ចាស់ស្រឡាញ់យើង និង មេត្តាករុណាដល់យើង ។



ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានអោយយើងមានភាពវិសុទ្ធរបស់ព្រះ-
យេស៊ូ ដើម្បីសង្គ្រោះយើង ថែរក្សាយើង និង ដឹកនាំយើងអោយ
ធ្វើអំពើល្អ ។ យើងបានវិសុទ្ធ ដោយសារព្រះគ្រីស្ត ។

ដោយសារតែអាដាមមិនស្តាប់បង្គាប់ ទើបយើងគ្រប់គ្នាសុទ្ធតែ
ប្រព្រឹត្តអំពើបាប និង ត្រូវស្លាប់ ។ ប៉ុន្តែ តាមរយៈការស្តាប់បង្គាប់
របស់ព្រះគ្រីស្ត អ្នកជឿគ្រប់រូបនឹងបានទទួលជីវិតអស់កល្ប ។
ព្រះយេស៊ូគ្រីស្តបានសុគតលើឈើឆ្កាង ដើម្បីលោះបាបយើង
ហើយមានព្រះជន្មរស់ឡើងវិញ ដើម្បីអោយអ្នកជឿលើព្រះអង្គ
មានជីវិតថ្មី និង វិសុទ្ធរួមជាមួយព្រះអង្គ ។

ការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ
មានឥទ្ធិពលលើយើង តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ។ ព្រះអង្គ :

☐ ជួយយើងតែនៅពេលចាប់ផ្តើមជីវិតជាគ្រីស្តជនប៉ុណ្ណោះ ។

☐ ជួយយើងអោយចាប់ផ្តើម និង តស៊ូព្យាយាម ។

កិច្ចការរបស់ព្រះគ្រីស្ត គឺថែរក្សាយើងជារៀងរហូត ។ ព្រះវិញ្ញាណ
ដ៏វិសុទ្ធបង្រួបបង្រួមយើងជាមួយព្រះគ្រីស្តរហូតអស់កល្ប ។

ឥឡូវនេះ ជនជាតិអ៊ីស្រាអែលដ៏ពិត មិនមែនជាពូជពង្សខាងសាច់
ឈាមរបស់លោកអប្រាហាំទេ តែជាពួកអ្នកដែលមានជំនឿលើ
សេចក្តីសន្យារបស់ព្រះជាម្ចាស់ ដូចលោកអប្រាហាំទៅវិញទេ ។

*«...ព្រោះអស់អ្នកដែលកើតមកពីពូជពង្សលោកអ៊ីស្រាអែល មិន
មែនសុទ្ធតែជាសាសន៍អ៊ីស្រាអែលពិតប្រាកដឡើយ ហើយអស់
អ្នកដែលកើតពីពូជពង្សរបស់លោកអប្រាហាំ ក៏មិនមែនសុទ្ធតែជា
កូនចៅរបស់លោកអប្រាហាំទាំងអស់គ្នាដែរ ដូចមានថ្លែងទុកមក
ថា"មានតែកូនចៅអ៊ីសាក់ប៉ុណ្ណោះ ដែលមានឈ្មោះថាជាពូជពង្ស
របស់អ្នក" ពោលគឺមិនមែនកូនចៅដែលកើតមកតាមសាច់ឈាម
ធម្មតានោះទេ ដែលត្រូវរាប់ជាបុត្រធីតារបស់ព្រះជាម្ចាស់ មានតែ
កូនចៅ ដែលកើតមកតាមព្រះបន្ទូលសន្យាប៉ុណ្ណោះ ទើបរាប់ជា
ពូជពង្សបាន»* ។

(រ៉ូម ៩:៦-៨)

បើតាមសេចក្តីខាងលើនេះ តើអ្នកជាកូនចៅលោកអប្រាហាំដែរ
ឬទេ ? ។_____

ជំហាន ទី ៥ : អ្នកជឿបានជាប់ឆ្កាងជាមួយព្រះគ្រីស្ត ហើយ រស់ឡើងវិញ ដើម្បីអោយមានជីវិតថ្មី ។
(អានជំពូក ៦)



និមិត្តរូបអំពីការស្លាប់រួមជាមួយព្រះគ្រីស្ត

ជំហាន ទី ៩ : មនុស្សដែលរស់នៅតាមព្រះវិញ្ញាណ ពេញចិត្តនឹងឫសគល់ខាងព្រលឹងវិញ្ញាណរបស់ខ្លួន
(អានជំពូក ៩-១១)

លោកប៉ូលមានទុក្ខព្រួយជាខ្លាំង ហើយឈឺចុកចាប់ក្នុងចិត្តជានិច្ច ព្រោះជនជាតិអ៊ីស្រាអែល ជាសាច់សាលោហិតរបស់លោក បែកចេញពីព្រះគ្រីស្ត (៩:១-៣) ។

សូមគូសពីក្រោមកិត្តិយសទាំងប្រាំបី ដែលព្រះជាម្ចាស់ប្រទានឱ្យជនជាតិអ៊ីស្រាអែល :

«...ព្រះជាម្ចាស់បានរាប់ពួកគេទុកជាបុត្រធីតារបស់ព្រះអង្គ ពួកគេមានសិរីរុងរឿង មានសម្ពន្ធមេត្រីនានា មានគម្ពីរវិន័យ ស្គាល់របៀបគោរពបំរើព្រះអង្គ ទទួលព្រះបន្ទូលសន្យាផ្សេងៗ មានបុព្វបុរស ហើយព្រះគ្រីស្តក៏កើតមកជាមនុស្ស ក្នុងពូជពង្សរបស់ពួកគេថែមទៀតផង ព្រះអង្គជាព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់លើអ្វីៗទាំង-អស់ សូមលើកតម្កើងព្រះអង្គអស់កល្បជានិច្ច អាម៉ែន !» ។

(រ៉ូម ៩:៤-៥)

បើសិនជាយើងស្លាប់ជាមួយព្រះគ្រីស្តពីអំពើបាប យើងក៏រស់ឡើងវិញជាមួយព្រះអង្គ ដើម្បីមានជីវិតថ្មី ដែលអស់កល្បដែរ ។

តើអ្នកជឿរស់ឡើងវិញ ដោយរបៀបណា ?

☐ អ្នកជឿស្លាប់ពីអំពើបាប និង រស់ឡើងវិញរួមជាមួយព្រះគ្រីស្ត ដើម្បីមានជីវិតថ្មី ។

☐ អ្នកជឿរស់ឡើងវិញ ដោយសារការប្រព្រឹត្តអំពើល្អរបស់ខ្លួន ។

សូមប្រៀបធៀបចំលើយរបស់អ្នកជាមួយបទគម្ពីរ :

«ហេតុនេះ ដោយពិធីជ្រមុជទឹក ដើម្បីរួមស្លាប់ជាមួយព្រះអង្គ យើងដូចជាបានចូលទៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ ។ ដូច្នេះ ព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ ដោយសារសិរីរុងរឿងរបស់ព្រះបិតាយ៉ាងណា យើងក៏រស់នៅតាមរបៀបថ្មីយ៉ាងនោះដែរ ។ ដូច្នេះ ប្រសិនបើយើងរួមស្លាប់ជាមួយព្រះគ្រីស្ត យើងក៏ជឿថា យើងនឹងមានជីវិតរួមជាមួយព្រះអង្គដែរ » ។

(រ៉ូម ៦:៤, ៨)

ពិធីជ្រមុជទឹកជានិមិត្តរូបអំពីជំនឿរបស់យើងលើព្រះគ្រីស្ត ។ យើងបានសង្គ្រោះ ដោយសារជំនឿនេះដែរ ។

យើងបានសង្គ្រោះដោយសារជំនឿ ហើយបន្ទាប់ពីថ្វាយខ្លួនហើយ :

☐ យើងបន្តរស់ ដោយជំនឿ ។

☐ យើងចាប់ផ្តើមពឹងលើការប្រព្រឹត្តអំពើល្អរបស់ខ្លួនវិញ ។

យើងរស់ជានិច្ចដោយជំនឿ ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធគង់សណ្ឋិតក្នុងយើង ។

© Project WorldReach © SEAN

ដំណាក់ការរីកចំរើនឡើង

(ជំពូក ៧-១១)

ជំហាន ទី ៧ : មនុស្សដែលរស់នៅតាមព្រះវិញ្ញាណ តយុទ្ធនឹងនិស្ស័យខាងសាច់ឈាមរបស់ខ្លួន ។

(អានជំពូក ៧)

រ៉ូម ជំពូក ៧ ចែងអំពីក្រិត្យវិន័យបីប្រភេទ :

១- ក្រិត្យវិន័យរបស់លោកម៉ូសេ (នៅក្នុងសម្ពន្ធមេត្រីចាស់) ។

២- ក្រិត្យវិន័យរបស់ព្រះវិញ្ញាណ (នៅក្នុងសម្ពន្ធមេត្រីថ្មី) ។

៣- ក្រិត្យវិន័យនៃអំពើបាប (និស្ស័យសាច់ឈាមរបស់យើង) ។

អ្នកជឿស្ថិតនៅក្រោមអំណាចនៃក្រិត្យវិន័យរបស់ :

☐ លោកម៉ូសេ ។

☐ ព្រះវិញ្ញាណ ។

☐ សាច់ឈាម ។



សូមផ្ទៀងចំលើយរបស់អ្នកជាមួយបទគម្ពីរនេះ :

«តែឥឡូវនេះ ដោយយើងបានស្លាប់រួចផុតពីវិន័យហើយ គឺរួចផុតពីអ្វីៗដែលបានឃុំឃាំងយើង ដូច្នេះ យើងបំរើព្រះជាម្ចាស់ តាមរបៀបថ្មី ដែលមកពីព្រះវិញ្ញាណ មិនមែនបំរើតាមរបៀបចាស់ដែលមកពីវិន័យសរសេរជាលាយលក្ខណ៍អក្សរនោះឡើយ » ។

(រ៉ូម ៧:៦)

«ដូច្នេះ ចំពោះខ្ញុំដែលចង់ធ្វើអំពើល្អ ខ្ញុំសង្កេតឃើញមានគោលការណ៍មួយនេះថា ខ្ញុំមានសមត្ថភាពធ្វើបានតែអំពើអាក្រក់ប៉ុណ្ណោះ ។ ក្នុងជំរៅចិត្តរបស់ខ្ញុំ ខ្ញុំពេញចិត្តនឹងវិន័យរបស់ព្រះជាម្ចាស់ណាស់ ក៏ប៉ុន្តែ ខ្ញុំឃើញថា នៅក្នុងសរីរាង្គកាយរបស់ខ្ញុំ មានគោលការណ៍មួយទៀត ដែលតយុទ្ធនឹងវិន័យនៃគំនិតប្រាជ្ញារបស់ខ្ញុំ ទាំងធ្វើអោយខ្ញុំជាប់ជាឈ្លើយរបស់បាបដែលស្ថិតនៅក្នុងសរីរាង្គកាយរបស់ខ្ញុំ ថែមទៀតផង » ។

(រ៉ូម ៧:២១-២៣)

នៅពេលដែលយើងរួមស្លាប់ជាមួយព្រះគ្រីស្ត យើងស្លាប់ពីអំពើបាប និង ពីក្រិត្យវិន័យ ។ យើងលែងធ្វើតាមក្រិត្យវិន័យ ដែលជាទម្លាប់នៅក្នុងសម្ពន្ធមេត្រីចាស់ទៀតហើយ គឺយើងដើរតាមព្រះវិញ្ញាណវិញ ។

(សូមផ្ទៀងចំលើយរបស់អ្នកជាមួយ រ៉ូម ៨:២៨-៣០ និង អេភេសូ ១:៣-៤) ។

សូមគូសពីក្រោមសេចក្តីដប់យ៉ាង ដែលយើងអាចឈ្នះ ដោយ-សារព្រះគ្រីស្ត :

«ខ្ញុំជឿជាក់ថា ទោះបីសេចក្តីស្លាប់ក្តី ជីវិតក្តី ទេវទូតក្តី វត្ថុសក្តិសិទ្ធិនានាក្តី បច្ចុប្បន្នកាលក្តី អនាគតកាលក្តី អំណាចនានាក្តី អ្វីៗដែលនៅស្ថានលើក្តី នៅស្ថានក្រោមក្តី ឬ អ្វីៗផ្សេងទៀតដែលព្រះជាម្ចាស់បង្កើតមកក្តី ក៏ពុំអាចបំបែកយើងចេញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលទ្រង់បានសំដែងឱ្យយើងឃើញក្នុងព្រះគ្រីស្តយេស៊ូជាអម្ចាស់នៃយើងបានឡើយ » ។

(រ៉ូម ៨:៣៨-៣៩)

យើងបានសង្គ្រោះក្នុងព្រះគ្រីស្ត :

☐ ជារៀងរហូត ។

☐ តែមួយរយៈប៉ុណ្ណោះ ។

សូមផ្ទៀងចំលើយរបស់អ្នកជាមួយ រ៉ូម ៨:២៨-៣០ និង រ៉ូម ៨:៣៨-៣៩ និង ហេប្រឺ ៩:១២ ។

© Project WorldReach © SEAN

សូមគូសពីក្រោមសេចក្តីប្រាំយ៉ាង ដែលព្រះជាម្ចាស់ធ្វើ ដើម្បីបញ្ជាក់ថា យើងបានសង្គ្រោះជារៀងរហូត :

«យើងដឹងទៀតថា អ្វីៗទាំងអស់ផ្សំគ្នាឡើង ដើម្បីអោយអស់អ្នកស្រឡាញ់ព្រះជាម្ចាស់ បានទទួលផលល្អ គឺអ្នកដែលព្រះអង្គបានត្រាស់ហៅមក ស្របតាមគំរោងការរបស់ព្រះអង្គ ដ្បិតអស់អ្នកដែលព្រះអង្គបានជ្រើសរើស ទ្រង់ក៏បានតំរូវគេទុកជាមុនឱ្យមានលក្ខណៈដូចព្រះបុត្រារបស់ព្រះអង្គដែរ ដើម្បីអោយព្រះបុត្រាបានទៅជារៀមច្បង ក្នុងបណ្តាបងប្អូនជាច្រើន ។ អស់អ្នកដែលព្រះ-អង្គបានតំរូវទុកជាមុននោះ ទ្រង់ក៏បានត្រាស់ហៅ ហើយអ្នកដែលព្រះអង្គបានត្រាស់ហៅនោះ ទ្រង់ក៏ប្រោសអោយគេបានសុចរិត រីឯអស់អ្នក ដែលព្រះអង្គប្រោសអោយបានសុចរិត ទ្រង់ក៏ប្រទានអោយគេមានសិរីរុងរឿងដែរ » ។

(រ៉ូម ៨:២៨-៣០)

ព្រះអង្គ «តំរូវទុកជាមុន» មានន័យថា :

☐ ដោយសារព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ ព្រះ-ជាម្ចាស់ជ្រើសរើសយើង តាំងពីមុនយើងទទួលព្រះគ្រីស្ត ។

☐ យើងសំរេចចិត្តខ្លួនឯងជ្រើសរើសទទួលព្រះគ្រីស្តមុន ។

អ្នកជឿដែលបានសង្គ្រោះ មាន :

☐ ក្រិត្យវិន័យដឹកនាំ ។

☐ ព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំ ។

ជំហាន ទី ៨ : មនុស្សដែលរស់នៅតាមព្រះវិញ្ញាណមាន សុវត្ថិភាព ដោយសារព្រះគ្រីស្ត ។
(អានជំពូក ៨)

ជំពូក ទី ៨ ធ្វើឱ្យចិត្តរបស់គ្រីស្តជនស្ងប់ លែងមានការព្រួយបារម្ភខ្លាំងៗ ។ ជំពូក ទី ៨ ធ្វើឱ្យគ្រីស្តជនលែងភ័យខ្លាចការកាត់ទោស សេចក្តីស្លាប់ ភាពទន់ខ្សោយ ឬ ការចោទប្រកាន់របស់មារសត្រូវទៀត ។ ជំពូក ទី ៨ ពន្យល់ពីរបៀប ដែលព្រះវិញ្ញាណធ្វើអោយការងាររបស់ព្រះគ្រីស្តបានសំរេច នៅក្នុងជីវិតគ្រីស្តជនយ៉ាងពេញលេញ និង ជារៀងរហូត ។

ពេលដែលយើងចូលរួមជាមួយព្រះគ្រីស្ត តើយើងបានរួចពីអ្វី ? (៨:១) ។ _____

_____

© Project WorldReach © SEAN

បើសិនជាយើងមានជីវិតក្នុងអង្គព្រះគ្រីស្ត តើព្រះវិញ្ញាណដ៏វិសុទ្ធ
រំដោះយើង អោយរួចពីសេចក្តីពីរយ៉ាងណាខ្លះ ? (៨:២) ។

រួចផុតពី_____និង ពី _____ ។

តើអ្នកណាជាជង្វាយសំរាប់លោះបាប ? (៨:៣-៤) ។ _____

_____

តើព្រះវិញ្ញាណដ៏វិសុទ្ធ ធ្វើអោយយើងមានបំណងគិតតែអំពីអ្វី ?
(៨:៥-៨) ។ _____

តើអ្នកណាជួយយើង មិនអោយរស់នៅតាមបែបលោកីយ៍ទៀត ?
(៨:៩-១១) ។ _____

ព្រះវិញ្ញាណជួយយើងអោយអាចរស់ « តាមព្រះវិញ្ញាណ »
(សូមអាន កាឡាទី ៥:២២-២៣) ។

តើយើងត្រូវរំលាយអ្វី តាមរយៈព្រះវិញ្ញាណ ? (៨:១២-១៣) ។

_____

*ស្លាប់ជាមិនខាន ផ្ទុយទៅវិញ ប្រសិនបើបងប្អូនពឹងផ្អែកលើព្រះ
វិញ្ញាណ ដើម្បីរំលាយរបៀបរស់នៅតាមលោកីយ៍ បងប្អូនមុខតែ
មានជីវិត ជ្បិតអស់អ្នកដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ណែនាំ
សុទ្ធតែជាបុត្រធីតារបស់ព្រះជាម្ចាស់ ។ បងប្អូនពុំបានទទួល
វិញ្ញាណដែលធ្វើអោយបងប្អូនទៅជាខ្ញុំបំរើ ហើយអោយនៅតែភ័យ
ខ្លាចទៀតទេ គឺបងប្អូនបានទទួលព្រះវិញ្ញាណ ដែលធ្វើអោយបង
ប្អូនទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ។ ដោយសារព្រះវិញ្ញាណ
នេះ យើងបន្លឺសំឡេងឡើងថា "អប្បា !" ឱព្រះបិតា ! គឺ
ព្រះវិញ្ញាណផ្ទាល់ ដែលផ្តល់សក្ខីភាពអោយវិញ្ញាណរបស់យើង
ដឹងថា យើងពិតជាបុត្រធីតារបស់ព្រះជាម្ចាស់មែន »* ។

(រ៉ូម ៨:៩-១៦)

តើយើងបានទទួលលទ្ធផលនៃកិច្ចការប្រោសលោះរបស់ព្រះគ្រីស្ត
ជារៀងរហូត ដោយសារអ្នកណា ?

☐ ខ្លួនឯង ។

☐ លោកពេត្រុស ឬ សាវ័កខ្លះទៀត ។

☐ ព្រះវិញ្ញាណដ៏វិសុទ្ធ ។

សូមផ្ទៀងចំលើយរបស់អ្នកខាងក្រោមនេះជាមួយ រ៉ូម ៨:៩-១៦ ។

សូមគូសពីក្រោមកិច្ចការប្រាំយ៉ាង ដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើក្នុងយើង និង ដើម្បីយើង :

«ចំពោះបងប្អូន ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ សណ្ឋិតនៅក្នុងបងប្អូន បងប្អូនមិនមែននៅខាងលោកីយ៍ទៀតទេ គឺនៅខាងព្រះវិញ្ញាណ ។ អ្នកណាគ្មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ត អ្នកនោះមិនមែនជាកូនចៅរបស់ព្រះអង្គទេ ។ ប្រសិនបើព្រះគ្រីស្តគង់នៅក្នុងបងប្អូន ទោះបីរូបកាយរបស់បងប្អូនស្លាប់ ព្រោះតែបាបក៏ដោយ ក៏ព្រះវិញ្ញាណនៅតែផ្តល់ជីវិតអោយបងប្អូនដែរ មកពីព្រះជាម្ចាស់ប្រោសបងប្អូនអោយបានសុចរិត ។ ប្រសិនបើព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលបានប្រោសព្រះយេស៊ូអោយមានព្រះជន្មរស់ឡើងវិញ សណ្ឋិតនៅក្នុងបងប្អូនមែននោះ ព្រះជាម្ចាស់ ដែលបានប្រោសព្រះគ្រីស្តអោយមានព្រះជន្មរស់ឡើងវិញ ទ្រង់ក៏នឹងប្រទានអោយរូបកាយរបស់បងប្អូន ដែលរមែងតែងតែស្លាប់នេះ មានជីវិតតាមរយៈព្រះវិញ្ញាណ ដែលសណ្ឋិតនៅក្នុងបងប្អូននោះដែរ ។ ហេតុនេះ បងប្អូនអើយ យើងមានជំពាក់ម្យ៉ាង តែមិនមែនជំពាក់ខាងលោកីយ៍ ដើម្បីរស់តាមលោកីយ៍ទៀតឡើយ ។ ប្រសិនបើបងប្អូនរស់តាមលោកីយ៍ បងប្អូននឹងត្រូវ

តើអ្នកណាជាបុត្រធីតារបស់ព្រះជាម្ចាស់ ? (៨:១៤) ។

_____

តើព្រះវិញ្ញាណដែលយើងបានទទួល ជាវិញ្ញាណប្រភេទណា ? (៨:១៥) ។ _____

តើព្រះវិញ្ញាណផ្តល់សក្ខីភាពអោយវិញ្ញាណយើងដឹងពីអ្វី ? (៨:១៦) ។ អោយយើងដឹងថា យើងពិតជា _____

_____

តើទុក្ខលំបាករបស់យើងនាបច្ចុប្បន្នកាលនេះ ពុំអាចប្រៀបផ្ទឹមនឹងអ្វី ? (៨:១៨-២៣) ។_____

តើនឹងមានរឿងអ្វីកើតឡើងចំពោះពិភពលោកនេះ នៅពេលដែលព្រះជាម្ចាស់ប្រោសរូបកាយយើងអោយរស់ឡើងវិញ ? (៨:១៩-២៤) ។ _____

_____

តើព្រះវិញ្ញាណធ្វើដូចម្តេច ដើម្បីជួយយើង នៅពេលដែលយើងទន់ខ្សោយ ? (៨:២៦-២៧) ។ _____

_____

_____

_____

ព្រះជាម្ចាស់កែប្រែយើងបន្តិចម្តងៗ តាមរយៈកាលៈទេសៈនិមួយៗ និង ហេតុការណ៍គ្រប់យ៉ាង ដែលកើតមានចំពោះយើង ។ តើព្រះជាម្ចាស់តំរូវយើងទុកជាមុន អោយមានលក្ខណៈដូចអ្នកណា ? (៨:២៨-២៩) ។_____

(វិចិត្រករខំឆ្លាក់សូន្យរូបអោយបានល្អប្រណិតយ៉ាងណា ព្រះជាម្ចាស់ក៏កែប្រែយើង អោយមានលក្ខណៈដូចព្រះបុត្រារបស់ព្រះអង្គយ៉ាងនោះដែរ ។ ជួនកាល ដំណើរការកែប្រែធ្វើអោយយើងមានការឈឺចាប់ ! ព្រោះព្រះជាម្ចាស់ប្រើបញ្ហា ដើម្បីធ្វើអោយយើងបានគ្រប់លក្ខណ៍) ។

តើព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់នឹងការចោទប្រកាន់ និងការដាក់ទោសរបស់អ្នកដទៃចំពោះយើងដែរឬទេ ? (៨:៣១-៣៤) ។ _____

(បើសិនជាយើងបានកែប្រែចិត្តគំនិត និង ទទួលជឿលើព្រះយេស៊ូហើយ ទាំងវិញ្ញាណអាក្រក់ ទាំងសត្រូវរបស់យើង និង ទាំងមនសិការរបស់យើងមិនអាចចោទប្រកាន់យើងនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ទេ) ។

តើមានអ្វីអាចបំបែកយើង ចេញពីព្រះគ្រីស្តបានដែរឬទេ ? (៨:៣៥-៣៩) ។ _____

ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការក្នុងយើង ដើម្បីកែប្រែជីវិតយើង :

☐ គ្រប់ជ្រុងជ្រោយ ។

☐ តែមួយផ្នែកតូច ។

ព្រះវិញ្ញាណដ៏វិសុទ្ធ បន្តធ្វើការកែប្រែជីវិតយើង ក្រោយពីយើងថ្វាយខ្លួន ។ មានផ្នែកជាច្រើនក្នុងជីវិតរបស់យើង ដែលព្រះជាម្ចាស់ត្រូវបំផ្លាស់បំប្រែ ប្រោសអោយបានវិសុទ្ធ និង កសាងបន្តិចម្តងៗ ដើម្បីអោយយើងកាន់តែមានលក្ខណៈដូចព្រះគ្រីស្ត ។